# សេចក្តីប្រកាសព័ត៌មាន

នាព្រឹកថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០១៨ **ឯកឧត្តម ជា សុផារ៉ា** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំ**ដែនដី នគរូបនីយកម្ម និងសំណង់** បានជួបជាមួយតំណាងប្រជាពលរដ្ឋ ៣១៧ គ្រួសារ ដែលមានវិវាទដីធ្លីជាមួយក្រុមហ៊ុន Koh Kong Plantation Co.,Ltd និងក្រុមហ៊ុន Koh Kong Sugar Industry Co.,Ltd ស្ថិតនៅស្រុកស្រែអំបិល និងស្រុកបុទុមសាគរ ខេត្តកោះកុង។ ដោយក្រុមការងារមមាញឹកក្នុងការវាស់វែងបែងចែកដីធ្លីជូនក្រុមប្រជាពលរដ្ឋ ២០០ គ្រួសារ ដែលទើបបានចាប់ឆ្នោតជ្រើសរើសឡូតិ៍រួចរាល់ និងជូនក្រុមប្រជាពលរដ្ឋ ១៧៥ គ្រួសារ ដែលជិតនឹងបានបញ្ចប់ ក្រុមការងារនឹងបន្តចាត់ចែងបែងចែកដីឡូតិ៍សម្រាប់ក្រុមប្រជាពលរដ្ឋ ៣១៧ គ្រួសារ ក្រុមប្រជាពលរដ្ឋ ១៧០ គ្រួសារ និងក្រុមប្រជាពលរដ្ឋ ៩៨ គ្រួសារទៀត សរុបចំនួន ៥៨៥ គ្រួសារ ដែលគ្រោងចុះវាស់វែងបែងចែកដីឡូតិ៍ឱ្យបានរួចរាល់ចន្លោះពីថ្ងៃទី ២០ ខែមិថុនា ដល់ដំណាច់ខែមិថុនានេះ។

អាស្រ័យហេតុនេះ សូមប្រជាពលរដ្ឋពាក់ព័ន្ធសហការជាមួយក្រុមការងារ ដើម្បីអាចសម្រេចកិច្ចការនេះតាមផែនការគ្រោង។

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០១៨


អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com